www.kidworship.kr

# ចំណងជើង៖ បុរសនេសាទត្រី



22Page

Narration — នៅថ្ងៃមួយព្រះយេស៊ូបានយាងចេញទៅខាងក្រៅនៅឯនាយសមុទ្រ កាលីឡេ
ពេលនោះមានបុរសម្នាក់ឈ្មោះ ពេត្រុស គាត់គឺជាអ្នកនេសាទត្រី។
គាត់កំពុងតែនេសាទត្រីជាមួយប្អូនប្រុសរបស់គាត់គឺអនទ្រេ។

ពេត្រុស — គ្មានត្រីទាល់តែសោះ! យើងចាប់ត្រីពេញមួយយប់ហើយ ប៉ុន្តែមិនបានត្រីសូម្បីតែមួយ!
ហ៊ើយ!!!!!

Narration — ពេត្រុស និងអនទ្រេមានការខកចិត្តជាខ្លាំង
ហើយក៏យកទូករបស់ពួកគេមកឯខាងនាយសមុទ្រ
រួចក៏លាងសំអាតអួនរបស់ពួកគេចេញ។

---



23Page

Narration — ព្រះយេស៊ូបានយាងមកឯនាយសមុទ្រ។ មានហ្វូងមនុស្សជាច្រើនបានដើរតាមទ្រង់
ពេលនោះព្រះយេស៊ូបានយាងចូលទៅក្នុងទូករបស់ពេត្រុស ហើយមានព្រះបន្ទូលថា៖

ព្រះយេស៊ូ — តើអ្នកអាចរុញទូកចេញពីច្រាំងបន្តិចបានទេ?

Narration — ពេត្រុសបានស្រាយខ្សែរទូក ហើយបានរុញទូកពីច្រាំងបន្តិចទៅឯទឹក
ដូច្នេះគ្រប់គ្នាទាំងអស់អាចមើលឃើញព្រះយេស៊ូដោយស្រួល។
ព្រះយេស៊ូបានមានព្រះបន្ទូលទៅកាន់ហ្វូងមនុស្សអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់។
នៅពេលដែលលោកពេត្រុសគាត់បាននេសាទត្រីរួចហើយ
ព្រះយេស៊ូបានមានព្រះបន្ទូលទៅកាន់គាត់ថា៖

ព្រះយេស៊ូ — “សូមអ្នកចេញទៅកន្លែងទឹកដែលជ្រៅ

ព្រះយេស៊ូ — ហើយទំលាក់អួនរបស់អ្នកចុះដើម្បីចាប់ត្រីទៅ”។



24Page

ពេត្រុស — លោកគ្រូ! ពួកយើងបានធ្វើការនេសាទពេញមួយយប់ហើយ
តែមិនបានត្រីទាល់តែសោះ
ប៉ុន្តែដោយលោកគ្រូមានប្រសាសន៍ដូច្នេះខ្ញុំនឹងទំលាក់អួនចុះ។

Narration — ពេត្រុស ហើយនិងអនទ្រេពួកគាត់គឺជាអ្នកនេសាទដ៏ជំនាញ
ប៉ុន្តែពួកគេបាននេសាទយ៉ាងហត់នឿយពេញមួយយប់
ដោយពុំបានត្រីមួយទាល់តែសោះ។ ស្រាប់តែព្រះយេស៊ូមានព្រះបន្ទូលទៅកាន់ពួកគេ
ពួកគេក៏ទំលាក់អួនចុះតែម្តង។ ពេត្រុសនិងអនទ្រេសើចញញឹមដាក់ព្រះយេស៊ូ
ពួកគេស្តាប់ទ្រង់និងធ្វើតាមអ្វីដែលទ្រង់មានព្រះបន្ទូល។

---



25Page

ពេត្រុស — វ៉ាវ! វ៉ាវ!! អូ វ៉ាវ! អីគេហ្នឹង? តើវាកើតឡើងដោយរបៀបណា?

Narration — ពេត្រុសនិងអនទ្រេ មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង។ អួនរបស់ពួកគេគឺពេញទៅដោយត្រី
ពួកគេបានចាប់ត្រីណាដែលធំៗ រហូតដល់រហែកអួនរបស់ពួកគេ។ ពេលនោះ
យ៉ាកុបហើយនិងយ៉ូហាន គឺជាអ្នកដែលនៅជិតកន្លែងនោះជាងគេ
ពួកគេបានឃើញពីអ្វីដែលបានកើតឡើង ហើយពួកគេក៏បានលុតជង្គង់ចុះ។
ព្រះយេស៊ូក៏មានព្រះបន្ទូលទៅពួកគេថា៖

ព្រះយេស៊ូ កុំខ្លាចអី! ចាប់ពីពេលនេះទៅ ខ្ញុំនឹងឲ្យអ្នកនេសាទមនុស្សវិញ
គឺមិនមែននេសាទត្រីទៀតទេ។

Narration ពួកគេបានទំលាក់អួននិងទូករបស់ពួកគេចោលនៅឯនាយសមុទ្រ
ហើយក៏បាននាំគ្នាដើរតាមព្រះយេស៊ូ។ ពេលនោះ ពេត្រុស,អនទ្រេ,យ៉ាកុបនិងយ៉ូហាន
បានក្លាយទៅជាសិស្សរបស់ព្រះយេស៊ូ។


26Page

Narration ថ្ងៃមួយព្រះយេស៊ូបានជួបជាមួយបុរសម្នាក់ឈ្មោះ ម៉ាថាយ
គាត់គឺជាអ្នកប្រមូលពន្ធ។នៅពេលនោះ អ្នកប្រមូលពន្ធគឺជាមនុស្សដែលគេបានស្អប់
ដោយសារពួកគេបានប្រមូលប្រាក់យ៉ាងច្រើនពីប្រជាជន។ មនុស្សម្នាគ្រប់គ្នាបានគិតថា
លោកម៉ាថាយគឺជាមនុស្សមានបាប ប៉ុន្តែព្រះយេស៊ូបានចូលទៅកាន់លោកម៉ាថាយ
ហើយមានព្រះបន្ទូលទៅគាត់ថា៖

ព្រះយេស៊ូ សុំមកតាមខ្ញុំ!

Narration ម៉ាថាយបានក្រោកឈរ ទុកចោលអ្វីគ្រប់យ៉ាងហើយដើរតាមព្រះយេស៊ូ។
នៅពេលដែលពួកផារិស៊ី
បានឃើញព្រះយេស៊ូបរិភោគអាហារពេលល្ងាចនៅឯផ្ទះរបស់លោកម៉ាថាយដែលជាអ្ន
កយកពន្ធ និងជាមនុស្សមានបាប ពួកគេបានត្អូញត្អែរពីការនោះ។

ពួកផារិសី យេស៊ូ! ហេតុអ្វីបានជាអ្នកបរិភោគជាមួយនឹងមនុស្សមានបាបដូច្នេះ?

ព្រះយេស៊ូ ដ្បិតអ្នកជាគេមិនត្រូវការគ្រូពេទ្យឡើយ
ប៉ុន្តែអ្នកដែលឈឺទេតើដែលត្រូវការគ្រូពេទ្យនោះ។
ខ្ញុំមិនមែនមកដើម្បីនឹងហៅមនុស្សសុចរិតឡើយ
គឺខ្ញុំមកដើម្បីនឹងស្វែងរកមនុស្សមានបាបវិញ
នេះជាហេតុផលដែលខ្ញុំនៅជាមួយពួកគេ។


27Page

Narration ហើយទ្រង់បានហៅសិស្សទាំងដប់ពីរនាក់របស់ទ្រង់។សិស្សរបស់ទ្រង់បានដើរតាមព្រះ
អង្គអស់រយៈពេល បីឆ្នាំពួកគេបានរៀនអំពីទ្រង់យ៉ាងច្រើន។
បន្ទាប់ពីព្រះយេស៊ូបានត្រឡប់ទៅឯស្ថានបរមសុខវិញ
សិស្សរបស់ទ្រង់នៅតែបន្តធ្វើការរបស់ពួកគេ
ក្នុងការបង្រៀនដូចជាអ្វីដែលព្រះយេស៊ូបានធ្វើនៅលើផែនដី
ពួកគេបានអធិប្បាយអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ទៅកាន់អ្នកឈឺ និងអ្នកជា។